ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ : ០០៧/០៩ ប្រ.ក អ.ជ.ប.គ.ញ

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ
## មន្ទីរពិសោធន៍គ្រឿងញៀន
## នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

**ប្រការ ១** : ប្រកាសនេះ កំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។


អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ Phone / Fax: (855) 23 721 648 , 23 721 777. P.O. Box : 151
E-mail : info@nacd.gov.kh , Website : www.nacd.gov.kh

## អំពីតួនាទី និងភារកិច្ច :

**ប្រការ ២** : មន្ទីរពិសោធន៍គ្រឿងញៀនមាន តួនាទី និងភារកិច្ចដូចតទៅ:

- ធ្វើវិភាគស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ លើលក្ខណៈគីមី និងលក្ខណៈរូបនៃសារធាតុគ្រឿងញៀន និងគីមីផ្សំគ្រឿងញៀន ដែលកំណត់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា នៅក្នុងរុក្ខជាតិ សារធាតុគីមី វត្ថុធាតុដែលមាននៅក្នុងសរីរាង្គមនុស្ស ចំណីអាហារ ភេសជ្ជៈ និងឱសថ បុរាណ/សម័យ ។
- ធ្វើការវិភាគគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀន ដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចប្រគល់ជូន និង ផ្តល់ជូននូវលទ្ធផលនៃការវិភាគទាំងនោះវិញ ។
- ធ្វើការផលិតសារធាតុប្រតិករសំរាប់ធ្វើតេស្តពណ៌ជំហ៊ានដំបូងលើសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន ។
- ធ្វើការសិក្សាស្រាវជ្រាវរកសារធាតុញៀន ឬ សារធាតុគីមីផ្សំគ្រឿងញៀនថ្មី ឬសារធាតុពុលផ្សេងទៀត ដែលនាំអោយប៉ះពាល់ដល់សុខភាព ដើម្បីដាក់ចូលទៅក្នុងតារាងត្រួតពិនិត្យសារធាតុគ្រឿងញៀន នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួងសុខាភិបាល និង មន្ទីរពិសោធន៍ ផ្សេងៗទៀតដែលពាក់ព័ន្ធ ។
- ធ្វើការរក្សាទុក វិភាគ និងប្រៀបធៀបទិន្នន័យ ស្តីពីលក្ខណៈរូប លក្ខណៈគីមី ដើម្បីរកពត៌មានចាំបាច់ដែលពាក់ព័ន្ធ សំរាប់បំរើការងារស៊ើបអង្កេត ។
- លើកសំណើជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការផលិត និងការធ្វើជំនួញឱសថសម័យ ឱសថបុរាណ ភេសជ្ជៈ គ្រឿងស្រវឹង គ្រឿងបរិភោគនៅក្នុងប្រទេស និងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀនស្រាវជ្រាវរកឃើញថាមានសារធាតុញៀនលើសពីកំរិតសុវត្ថិភាព ដែលបង្កអោយមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពសង្គម ដើម្បីធ្វើការហាមឃាត់ ។
- គ្រប់គ្រងដឹកនាំមន្ទីរពិសោធន៍ភូមិភាគ និងការិយាល័យជំនាញក្រោមឱវាទលើផ្នែករដ្ឋបាល បច្ចេកទេស ឧបករណ៍ សំភារៈ និងការបណ្តុះបណ្តាលជំនាញក្នុងការធ្វើតេស្តវិភាគគ្រឿងញៀននិងវិភាគជាតិពុល ។

**ប្រការ ៣** : មន្ទីរពិសោធន៍គ្រឿងញៀន គ្រប់គ្រង និងដឹកនាំដោយប្រធានមន្ទីរពិសោធន៍១រូប និងមានអនុប្រធាន ជាជំនួយការ ។

ប្រធានមន្ទីរពិសោធន៍ត្រូវតែងតាំង ដោយអនុក្រឹត្យតាមសំណើរបស់អគ្គលេខាធិការដោយមានការយល់ព្រម ពីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនពីក្នុងចំណោមមន្ត្រីដែលមានជំនាញវិជ្ជាជីវៈផ្នែក

បច្ចេកទេសវិទ្យាសាស្ត្រ (វិស្វករគីមី ឬ ឱសថការីឧត្តម) និងមានឋានន្តរសក្តិវរៈមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬ នាយនគរបាលជាតិជាន់ខ្ពស់ចាប់ពីថ្នាក់ឧត្តមសេនីយ៍ត្រី ។

អនុប្រធានមន្ទីរពិសោធន៍ ត្រូវតែងតាំងដោយប្រកាសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធានមន្ទីរពិសោធន៍ ដោយមានការឯកភាពពីអគ្គលេខាធិការ ក្នុងចំណោមមន្ត្រីដែលមានជំនាញវិជ្ជាជីវៈផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ (វិស្វករគីមី ឬ ឱសថការីឧត្តម) និងមានឋានន្តរសក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬ នាយនគរបាលជាតិជាន់ខ្ពស់ចាប់ពីថ្នាក់វរសេនីយ៍ឯក ។

**ប្រការ ៤** : ប្រធានមន្ទីរពិសោធន៍គ្រឿងញៀន ត្រូវបំពេញភារកិច្ចដូចខាងក្រោម:

- ទទួលខុសត្រូវលើការងារដំណើរការ និងគ្រប់គ្រងមន្ទីរពិសោធន៍ និងទទួលខុសត្រូវលើកិច្ចការនានាចំពោះមុខអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។
- រាយការណ៍ជូន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពីកិច្ចការនានាដែលទាក់ទងទៅនឹងការងារដំណើរការ និងគ្រប់គ្រងមន្ទីរពិសោធន៍ ។
- លើកសំណើអំពីការតែងតាំង ការតំឡើងឋានន្តរសក្តិ ឬ ផ្ទេរមន្ត្រីរាជការ ក្រោមឱវាទរបស់មន្ទីរពិសោធន៍ ។
- ចុះហត្ថលេខាលើគ្រប់ឯកសារ ដែលទាក់ទងទៅនឹងការងាររបស់មន្ទីរពិសោធន៍ ។
- មានសិទ្ធិធ្វើប្រតិភូកម្មអំណាចចុះហត្ថលេខា ដែលទាក់ទងកិច្ចការមន្ទីរពិសោធន៍ដល់អនុប្រធានមន្ទីរពិសោធន៍ ។

**ប្រការ ៥** : អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន ត្រូវបំពេញភារកិច្ចដូចខាងក្រោម:

- ទទួលខុសត្រូវចំពោះមុខប្រធានមន្ទីរពិសោធន៍ ចំពោះកិច្ចការនានាដែលស្ថិតក្រោមការទទួលខុសត្រូវឬសមត្ថកិច្ចរបស់ខ្លួន ។
- មានសិទ្ធិចុះហត្ថលេខាលើឯកសារដែលទាក់ទងនឹងកិច្ចការរដ្ឋបាលក្រោមការធ្វើប្រតិភូកម្មពីប្រធានមន្ទីរពិសោធន៍ ។

## អំពីរចនាសម្ព័ន្ធ

**ប្រការ ៦** : មន្ទីរពិសោធន៍គ្រឿងញៀនមាន មន្ទីរពិសោធន៍ភូមិភាគចំនួនពីរ និងប្រាំការិយាល័យជាសេនាធិការ

-មន្ទីរពិសោធន៍ភូមិភាគ I

-មន្ទីរពិសោធន៍ភូមិភាគ II

-ការិយាល័យបច្ចេកទេស

-ការិយាល័យវិភាគវត្ថុជីវសាស្ត្រ

-ការិយាល័យវិភាគជាតិគីមីសរីរាង្គ និងសារធាតុពុល

-ការិយាល័យស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រគីមីថ្មី

-ការិយាល័យឯកសារ រដ្ឋបាល និងសំភារៈបច្ចេកទេស

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានការិយាល័យយ៉ាងច្រើនចំនួន ០៣ រូប ។ ប្រធានការិយាល័យត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធានមន្ទីរពិសោធន៍ ដោយមានការឯកភាពពីអគ្គលេខាធិការ ក្នុងចំណោមមន្ត្រីដែលមានជំនាញវិជ្ជាជីវៈផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ (អ្នកបច្ចេកទេសគីមី ឬ ឱសថការី ឬវិទ្យាសាស្ត្រសុខាភិបាល) និងមានឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ នាយនគរបាលជាតិថ្នាក់វរសេនីយ៍ទោ ។ អនុប្រធានការិយាល័យត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធានមន្ទីរពិសោធន៍ ដោយមានការឯកភាពពីអគ្គលេខាធិការ ក្នុងចំណោមមន្ត្រីដែលមានឋានន្តរស័ក្តិនាយក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ នាយនគរបាលជាតិថ្នាក់វរសេនីយ៍ត្រី ។

អង្គការលេខរបស់មន្ទីរពិសោធន៍គ្រឿងញៀនមានចែងជាឧបសម្ព័ន្ធភ្ជាប់ ។

## អំពីភារកិច្ចរបស់ការិយាល័យ

**ប្រការ ៧:** មន្ទីរពិសោធន៍ភូមិភាគ I-II ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

ធ្វើការវិភាគរកគុណភាព បរិមាណ សារធាតុញៀន សារធាតុគីមីផ្សំគ្រឿងញៀន ជូនស្ថាប័នមានសមត្ថកិច្ច រួចផ្តល់ជូននូវលទ្ធផលដែលបានមកពីការវិភាគត្រឡប់ទៅវិញ ។

**ប្រការ ៨:** ការិយាល័យបច្ចេកទេស ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ធ្វើការវិភាគរកគុណភាពនៃប្រភេទរបស់គ្រឿងញៀន
- ធ្វើការវិភាគរកបរិមាណភាពសុទ្ធនៃគ្រឿងញៀន
- ធ្វើការវិភាគរកគុណភាព និងបរិមាណភាពសុទ្ធ នៃសារធាតុគីមីផ្សំគ្រឿងញៀន
- ធ្វើការកំណត់ និងវាយតំលៃពីលក្ខណៈ និងបទដ្ឋានបច្ចេកទេសទាក់ទងទៅនឹងសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន
- ធ្វើការចងក្រងប្រមូលទិន្នន័យបច្ចេកទេសទុកជាឯកសារ និងផ្តល់ជូនសមត្ថកិច្ចអនុវត្តន៍ច្បាប់ដើម្បីប្រើប្រាស់ក្នុងការស៊ើបអង្កេត ឬផ្តន្ទាទោស ឬការផ្លាស់ប្តូរពត៌មាន ។
- ធ្វើការកំណត់ និងវាយតំលៃផ្នែកបច្ចេកទេស ពីការប្រើប្រាស់ ការនាំចេញ-នាំចូល ការចរាចរ ការលក់ដុំ ការលក់រាយ ការស្តុកទុកនិងការថែរក្សា រាល់សារធាតុញៀន និង សារធាតុគីមីផ្សំគ្រឿងញៀន ដោយរៀបចំអោយមានជាទិន្នន័យស្តីពីការគ្រប់គ្រងសារធាតុទាំងនោះ រួចធ្វើរបាយការណ៍ជូនអគ្គលេខាធិការ និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីត្រួតពិនិត្យជាប្រចាំ ។

- រៀបចំនូវបទដ្ឋានក្នុងការគ្រប់គ្រង និងប្រមូលទិន្នន័យជាលក្ខណៈបច្ចេកទេស ទាក់ទងទៅនឹងសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន (ជារុក្ខជាតិ ឬ ជាសារធាតុគីមី) ដើម្បីទុកជាឯកសារមូលដ្ឋាន និងសំរាប់បង្កភាពងាយស្រួលក្នុងការទប់ស្កាត់កុំអោយមានការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀន ពីជំនួញស្របច្បាប់នៅក្នុងប្រទេស ទៅជាជំនួញខុសច្បាប់ ។

**ប្រការ ៩:** ការិយាល័យវិភាគវត្ថុជីវសាស្ត្រ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ធ្វើការវិភាគរកសារធាតុប៉ះពាល់លើប្រព័ន្ធសរសៃប្រសាទ សារធាតុញៀនណាកូទិច និងសារធាតុគីមីពុលផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់មនុស្ស ឬ សត្វ ។
- ធ្វើការវិភាគរកសារធាតុញៀន និងជាតិពុលនានានៅក្នុងទឹកនោម ។
- ធ្វើការវិភាគរកសារធាតុញៀន និងជាតិពុលនានានៅក្នុងឈាម ។
- ធ្វើការវិភាគរកសារធាតុញៀន និងជាតិពុលនានានៅក្នុងជីវៈសរីរាង្គផ្សេងៗ ។

**ប្រការ ១០:** ការិយាល័យវិភាគជាតិគីមីសរីរាង្គ និងសារធាតុពុល ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ធ្វើការវិភាគរកសារធាតុគីមីសរីរាង្គ និងសារធាតុនានា ដែលស្ថាប័នមានសមត្ថកិច្ចមានការសង្ស័យពាក់ព័ន្ធក្នុងបទល្មើស ឬមានបំណងរកពតិមានដើម្បីបំរើអោយការងារស៊ើបអង្កេតឬផ្តន្ទាទោស ។
- ធ្វើការវិភាគរកសារធាតុគីមីសរីរាង្គ និងសារធាតុពុល ដែលសង្ស័យថាមានគេលួចលាក់ទុកនៅក្នុងភេសជ្ជៈ គ្រឿងស្រវឹង គ្រឿងបរិភោគ ឱសថបុរាណ ឬសម័យ និងវត្ថុធាតុផ្សេងៗ ។

**ប្រការ ១១:** ការិយាល័យស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រគីមីថ្មី ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ធ្វើការវិភាគលើលក្ខណៈរូប និងលក្ខណៈគីមី ស្តីពីភាពមិនសុទ្ធរបស់គ្រឿងញៀន
- ចងក្រងឯកសារប្រវត្តិនៃភាពមិនសុទ្ធរបស់គ្រឿងញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន
- ចងក្រងទិន្នន័យ នៃបទល្មើសដែលអាចជាប់ទាក់ទងគ្នារវាងសំណាកគ្រឿងញៀន ដើម្បីវាយតំលៃរកប្រភព ផ្លូវចរាចរ វិសាលភាពសាយភាយ និងវិធីសាស្ត្រដែលគេបានលួចផលិតគ្រឿងញៀនដោយខុសច្បាប់ និងការវាយតំលៃលើបុគ្គលដែលអាចពាក់ព័ន្ធក្នុងបទល្មើសគ្រឿងញៀន ។

**ប្រការ ១២:** ការិយាល័យឯកសារ រដ្ឋបាល និងសំភារៈបច្ចេកទេស ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ធ្វើការរៀបចំចងក្រងទុកដាក់ ចរាចរ ឯកសារឬលិខិតស្នាមផ្នែករដ្ឋបាល និងបច្ចេកទេស នៅក្នុងមន្ទីរពិសោធន៍គ្រឿងញៀន ។
- ធ្វើរបាយការណ៏រដ្ឋបាល និងបច្ចេកទេស ជូនប្រធានដើម្បីដាក់ជូនអគ្គលេខាធិការដ្ឋានពិនិត្យនិងសំរេច ។

- រៀបចំកម្មវិធីប្រជុំ ការគ្រប់គ្រងមន្ត្រីបុគ្គលិក លើកគំរោងចំណាយថវិកា សំភារៈ ប្រេងឥន្ធនៈ និង អនុវត្តភារកិច្ចផ្សេងៗទៀតសំរាប់ដំណើរការអនុវត្តន៏ការងារនៅក្នុងមន្ទីរពិសោធន៍គ្រឿងញៀនអោយបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ។
- ធ្វើការត្រួតពិនិត្យ ថែរក្សា ស្នើសុំនូវឧបករណ៍សំភារៈ សារធាតុគីមី ប្រតិករគីមី ថវិកា និង ប្រមូលទិន្នន័យបច្ចេកទេស សំរាប់ធានាអោយមាននិរន្តរភាពការងារនៅក្នុងមន្ទីរពិសោធន៏ ។
- ធ្វើការរៀបចំសេវាកម្មក្នុងការវិភាគសារធាតុគីមី ដោយសហការជាមួយផ្នែកជំនាញបច្ចេកទេស នៃក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ប្រការ១៣** : រាល់ប្រកាស ដីកា និងលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៤** : អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ប្រធាននាយកដ្ឋានប្រធានមន្ទីរពិសោធន៏ នៃអ.ជ.ប.គ.ញ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជា**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

ស ខេង

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

( *ដើម្បីជូនជ្រាប* ) ។

- ដូចប្រការ១៤ ( ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ
# មន្ទីរពិសោធន៍គ្រឿងញៀន

